YUNNAN DAILY PRESS GROUP
No.115

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY
PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7375 ថ្ងៃសុក្រ ទី07 ខែ កក្កដា ឆ្នាំ 2017

## អ្នកសារព័ត៌មានខ្មែរ ៖ បន្តពង្រឹងចំណងមិត្តភាពយូនណាន-កម្ពុជា



*អ្នកសារព័ត៌មានកម្ពុជាកំពុង សម្ភាសន៍ជាមួយនឹងពាណិជ្ជករកម្ពុជា នៅក្នុង អំឡុងព្រឹត្តិការណ៍ពិព័រណ៍ផលិតផល និងសិក្ខាសាលាស្តីពីការ វិនិយោគ និង ពាណិជ្ជកម្ម ប្រទេសអាស៊ី ខាងត្បូង និងអាស៊ីអាគ្នេយ៍២០១៧ ដែលរៀបចំ ពីថ្ងៃទី១២ដល់ទី១៨ ខែមិថុនា (រូបថត ដោយ Liu Rong )*

***ដោយ លីវ យ៉ុង***

នៅខែមិថុនា ឆ្នាំ២០១៣ ប្រទេសមហាអនុតំបន់ទន្លេមេគង្គទាំង៦ បានឯកភាពគ្នានៅក្នុងក្រុងគុនមីងនៃខេត្តយូនណានអំពីការបង្កើតយន្តការនៃការបំពេញទស្សនកិច្ចគ្នាទៅវិញទៅមកតាមពេលកំណត់រវាងប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសពាក់ព័ន្ធ ។ ក្នុងឱកាសពិព័រណ៍ផលិតផលនិងសិក្ខាសាលាស្តីពីការវិនិយោគនិងពាណិជ្ជកម្មប្រទេស អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ២០១៧ ដែលរៀបចំពីថ្ងៃទី១២ ដល់ទី១៨ ខែមិថុនា កន្លងទៅនោះអ្នកសារព័ត៌មាន ដែលមកពីប្រទេស កម្ពុជា ឡាវ ថៃ មីយ៉ាន់ម៉ា និងវៀតណាម បានជួបជុំគ្នាម្តងទៀតនៅក្រុងគុនមីងរួមគ្នាកសាងអនាគតថ្មីនៃប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសមហាអនុតំបន់ទន្លេមេគង្គ ។ អ្នកសារព័ត៌មានខ្មែរដែលចូលរួមក្នុងសកម្មភាពនេះបានកត់ត្រានិងពិពណ៌នាអំពីខេត្តយូនណានដោយប្រើប្រាស់ដងប៊ិក និងកាមេរ៉ារបស់ខ្លួន ។

លោក យ៉ែម ណយ ប្រធាននាយកដ្ឋានមណ្ឌលព័ត៌មាននៃក្រសួងព័ត៌មានកម្ពុជាមានប្រសាសន៍ថា នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ ការិយាល័យព័ត៌មាននៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន និងក្រសួងព័ត៌មានកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើការផ្លាស់ប្តូរវិស័យព័ត៌មាន ។ តាមរយៈការចុះអនុស្សរណៈនេះភាគីទាំងពីរ កម្ពុជា និងចិននឹងរួមគ្នាបង្កើនកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរលើវិស័យកម្មវិធីទូរទស្សន៍ ព័ត៌មានការយកបទសម្ភាសន៍និងការបំពេញទស្សនកិច្ចទៅវិញទៅមកជាដើម ។ ដូច្នេះយើងនឹងខិតខំពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការនេះ ។

ខេត្តយូនណានបានរួមវិភាគទានច្រើនក្នុងការបង្កើនការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការរវាងប្រព័ន្ធផ្សព្វផ្សាយចិន និងកម្ពុជា ហើយបាននិងកំពុងខិតខំប្រឹងប្រែងដើម្បីបង្កើតវេទិកាដ៏ធំមួយសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ។ លោក យ៉ែម ណយ បានលើកសំណើថា តាមរយៈទស្សនាវដ្តី "ខ្មែរ" សហភាពសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយបែបទំនើបយូនណាន-កម្ពុជា និងវេបសាយព័ត៌មានខ្មែរជាដើម ខេត្តយូនណាន និងប្រទេសកម្ពុជាអាចរួមសហការគ្នាចេញផ្សាយព័ត៌មានវប្បធម៌ និងទេសចរណ៍ជាភាសាចិន និងភាសាខ្មែរព្រមទាំងបង្កើតឃ្លាំងទិន្នន័យផ្តល់សេវាកម្ម ដើម្បីជំរុញការផ្សព្វផ្សាយ និងបង្កើនឥទ្ធិពលលើវិស័យទេសចរណ៍ និងវប្បធម៌ ។

នៅពេលដើរលេងក្រុងធឹងឈុងដែលស្ថិតនៅភាគខាងលិចនៃខេត្តយូនណាននោះ អ្នកសារព័ត៌មានខ្មែរបានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះទេសភាព ពិសេសនៅទីនោះ ។ លោក នឿត សុភ័ក្រ្ត អ្នកសារព័ត៌មានមកពីទីភ្នាក់ងារព័ត៌មានដើមអម្ពិលកម្ពុជា បានថ្លែងថា ធឹងឈុងជាក្រុងមួយដែលមានបរិស្ថានធម្មជាតិល្អប្រសើររួមមានតំបន់ដីសើម ប៉េហៃ សួនឃីហៃ និងសួនភ្នំភ្លើងជាដើម ។ កន្លែងទាំងនោះសុទ្ធតែមានអេកូ-បរិស្ថានដ៏ល្អប្រសើរ និងទាក់ទាញ ។ ចំណែកឃុំបុរាណហ៊ីសួនវាមានទេសភាពដូច "ស្រុកទឹកតំបន់ជាំងណាន" នៃប្រទេសចិន ។

លោក សែម សារ៉ាត់ អ្នកសារព័ត៌មានមកពី SABAY NEWS បានសម្តែងក្តីសង្ឃឹមរបស់លោកថា "ខ្ញុំសង្ឃឹមថាទំនាក់ទំនងរវាងខេត្តយូនណាន និងប្រទេសកម្ពុជាក៏ដូចជារវាងពួកយើងខ្ញុំ និងខេត្តយូនណាននោះនឹងអាចរីកចម្រើនល្អតលាស់បន្តទៅមុខពីមួយឆ្នាំទៅមួយឆ្នាំ "៕

## ក្រសួងពាណិជ្ជកម្មកម្ពុជា និងសាលាខេត្តជីលីនប្រទេសចិនរៀបចំសិក្ខាសាលាផ្លាស់ប្តូរទស្សនៈ



*ពិធីចុះហត្ថលេខា (រូបថត ដោយ Yu Jiangning )*

***ដោយ យូ ជាំងនីង***

នៅថ្ងៃទី២៩ ខែមិថុនា សិក្ខាសាលាស្តីពីការផ្លាស់ប្តូរទស្សនៈផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម កម្ពុជា-ខេត្ត ជីលីន ប្រទេសចិនបានប្រារព្ធនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងសិក្ខាសាលានេះភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការច្រើន ដែលពាក់ព័ន្ធនឹងគម្រោងគំរូអំពីការស្តុកស្បៀងអាហារជាតិកម្ពុជាគម្រោងសាងសង់តំបន់សហប្រតិបត្តិការកសិកម្ម សេដ្ឋកិច្ច និងពាណិជ្ជកម្មខេត្តជីលីន គម្រោងសាងសង់ផ្សារលក់បោះដុំក្នុងតំបន់ប្រព័ន្ធឡូជីស្ទីកអាស៊ីបូព៌ានៃប្រទេសកម្ពុជា គម្រោងផលិតម្សៅដំឡូងមីសរីរាង្គកម្ពុជា និងគម្រោងប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិចកម្ពុជាជា ដើម ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា បច្ចុប្បន្នប្រទេសកម្ពុជាកំពុងជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ដែលស៊ីសង្វាក់គ្នាកម្រិតខ្ពស់ទៅនឹងគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ដែលលើកឡើងដោយប្រទេសចិន ។ ប្រទេសកម្ពុជាបាននិងកំពុងក្លាយទៅជាទីដៅវិនិយោគដ៏ល្អប្រសើររបស់សហគ្រាសចិន ជាពិសេសសហគ្រិននិងវិនិយោគិនរបស់ប្រទេសចិនកាន់តែមានជំនឿចិត្តចំពោះការអភិវឌ្ឍនៃទីផ្សាររបស់ប្រទេសកម្ពុជា ៕

## សិក្ខាសាលាអ្នកសារព័ត៌មានមីយ៉ាន់ម៉ាឆ្នាំ២០១៧ប្រារព្ធនៅក្រុងគុនមីង

***ដោយ លីវ ជីយូ***

ក្នុងអំឡុងពេលពីថ្ងៃទី២៦ ខែមិថុនា ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០១៧ សិក្ខាសាលាអ្នកសារព័ត៌មានមីយ៉ាន់ម៉ាឆ្នាំ២០១៧ បានប្រារព្ធនៅក្រុងគុនមីងនៃខេត្តយូនណានប្រទេសចិន ។

គួរបញ្ជាក់ថា អ្នកសារព័ត៌មាន ២០រូប ដែលមកពីអង្គភាពសារព័ត៌មាន ចំនួន១៩នៃប្រទេសមីយ៉ាន់ម៉ា រួមមានក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយ ONLINE យុគសម័យប្រជាជនប្រទេសមីយ៉ាន់ម៉ា ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយ SHADE ក្រុបនៃប្រទេសមីយ៉ាន់ម៉ានិងទីភ្នាក់ងារព័ត៌មាន Narin Jara នៃប្រទេសមីយ៉ាន់ម៉ា ជាដើម បានចូលរួមក្នុងសិក្ខាសាលានេះ និងបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនិងសកម្មភាពផ្លាស់ប្តូរទស្សនៈផ្សេងៗ ដែលរៀបចំនៅក្រុងគុនមីង និងក្រុងប៉េកាំង ។

ក្នុងរយៈពេល១១ថ្ងៃនៃការរៀបចំសិក្ខាសាលានេះ អ្នកសារព័ត៌មានមីយ៉ាន់ម៉ាបានចូលរួមផ្លាស់ប្តូរទស្សនៈជាមួយមន្រ្តីរាជការ អ្នកជំនាញការ និងអ្នកសារព័ត៌មានចិនអំពីបញ្ហាសំខាន់មួយចំនួន ដែលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ទំនាក់ទំនងរវាងខេត្តយូនណានប្រទេសចិន និងប្រទេសមីយ៉ាន់ម៉ា និន្នាការអភិវឌ្ឍន៍នៃប្រព័ន្ធផ្សព្វផ្សាយទូទាំងពិភពលោក និងកិច្ចសហប្រតិបត្តិការអន្តរជាតិប្រព័ន្ធផ្សព្វផ្សាយជាដើម ។ លោកស្រី Latt Latt Soe សហលេខាធិការនៃសមាគមអ្នកសារព័ត៌មានមីយ៉ាន់ម៉ា បានបញ្ជាក់ថា តាមរយៈការចូលរួមសិក្ខាសាលានេះ សិក្ខាកាមមីយ៉ាន់ម៉ាបានទទួលចំណេះដឹងច្រើន ហើយសង្ឃឹមថា ភាគីចិននឹងអាចផ្តល់ឱកាសកាន់តែច្រើនដល់អ្នកសារព័ត៌មានមីយ៉ាន់ម៉ា ដើម្បីជំរុញឱ្យកាន់តែស៊ីជម្រៅនូវការផ្លាស់ប្តូររវាងប្រទេសទាំងពីរ ៕

## ក្រុមហ៊ុនអាកាសចរណ៍ស៊ីវិលក្រុងយូយលីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Boeing

***ដោយ ហ៊ូ សៀងយ៉ុង***

ក្នុងឱកាលពិព័រណ៍អាកាសចរណ៍ក្រុងប៉ារីសលើកទី៥២ ក្រុមហ៊ុនអាកាសចរណ៍ស៊ីវិលក្រុងយូយលីប្រទេសចិនបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនផលិតយន្តហោះ Boeing ដោយចុះអនុស្សរណៈស្តីពីការបញ្ជាទិញយន្តហោះប្រភេទថ្មី ៧៣៧-MAX ចំនួន២០គ្រឿង ដែលមានតម្លៃសរុប២.២០០លានដុល្លារអាមេរិក ស្មើនឹងប្រហែល១៥ពាន់លានយ័នប្រាក់ចិន។

បន្ទាប់ពីបើកធ្វើអាជីវកម្មនៅឆ្នាំ២០១៤រៀងមក ក្រុមហ៊ុនអាកាសចរណ៍ស៊ីវិលក្រុងយូយលីបានបើកខ្សែផ្លូវអាកាសចរណ៍ចំនួន២៨ខ្សែដោយមានជើងហោះហើរចំនួន៧៦ ជើងក្នុងមួយថ្ងៃ និងបានគ្របដណ្តប់លើទីក្រុងចំនួន២៧ ។ គួរបញ្ជាក់ថា ក្រុមហ៊ុនអាកាសចរណ៍ស៊ីវិលក្រុងយូយលីមានយន្តហោះ១៤គ្រឿងដែលសុទ្ធតែជាយន្តហោះរបស់ក្រុមហ៊ុន Boeing ៕

## ពាណិជ្ជករខ្មែរចាប់អារម្មណ៍ចំពោះឱកាសពាណិជ្ជកម្មនៃខេត្តយូនណាន

***ដោយ ជូ ហុងពីង លីវ យ៉ុង និង ស៊ីន យ៉ាន***

ក្នុងឱកាសពិព័រណ៍ផលិតផល និងសិក្ខាសាលាស្តីពីការវិនិយោគ និងពាណិជ្ជកម្មប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍២០១៧ ដែលរៀបចំពីថ្ងៃទី១២ដល់ទី១៨ ខែមិថុនាកន្លងទៅនោះ ពាណិជ្ជករខ្មែរបាននាំយកផលិតផលរបស់ខ្លួនមកដល់ក្រុងគុនមីងនៃខេត្តយូនណាន ដើម្បីធ្វើឱ្យមនុស្សកាន់តែច្រើនមានការយល់ដឹងអំពីប្រទេសកម្ពុជា ។ ពួកគេបានថ្លែងថា ពិព័រណ៍នេះគឺជាវេទិកាដ៏ល្អប្រសើរសម្រាប់អាជីវកម្មរបស់ខ្លួនហើយសង្ឃឹមថា នឹងអាចរកឃើញដៃគូពាណិជ្ជកម្មក្នុងពិព័រណ៍នេះ ដើម្បីផ្សាយលក់ទំនិញរបស់ខ្លួននៅក្នុងប្រទេសចិន ។

លោក មាស វីរក្ស ពាណិជ្ជករខ្មែរដែលធ្វើអាជីវកម្មលក់ដូរស្រាក្រហមបានមកចូលរួមពិព័រណ៍នៅក្រុងគុនមីងជាច្រើនដងហើយ ។ នៅឆ្នាំ២០១៥ លោកបានយកស្រាទំពាំងបាយជូរព្រៃមកចូលរួមពិព័រណ៍ផលិតផលអាស៊ីខាងត្បូង។កាលនោះស្រារបស់លោកបានទទួលការពេញនិយមនិងបានលក់អស់ក្នុងពិព័រណ៍លើកនោះ ។ ឆ្នាំនេះលោកសម្រេចចិត្តមកក្រុងគុនមីងម្តងទៀត ។ លោកនិយាយថា ស្រាទំពាំងបាយជូររបស់យើងខ្ញុំបានត្រូវនាំចេញទៅដល់ប្រទេស ថៃ វៀតណាម និងខេត្តក្វាងស៊ីនៃប្រទេសចិន ។ ខ្ញុំសង្ឃឹមថា នឹងអាចរកឃើញដៃគូពាណិជ្ជកម្មក្នុងពិព័រណ៍នេះ ដើម្បីផ្សាយលក់ស្រាទំពាំងបាយជូរខ្មែរនៅតាមទីផ្សារនៃខេត្តយូនណាន ។



*មន្ត្រីអ្នកត្រួតពិនិត្យគុណភាព ចិនកំពុងតែពិនិត្យទំនិញតាំងពិព័រណ៍ កម្ពុជានៅក្នុងអំឡុងព្រឹត្តិការណ៍ ពិព័រណ៍ផលិតផល និងសិក្ខាសាលាស្តីពីការវិនិយោគ នឹងពាណិជ្ជកម្ម ប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ២០១៧ ដែលរៀបចំ ពីថ្ងៃទី១២ ដល់ ទី១៨ ខែមិថុនា (រូបថត ដោយ Zu Hongbing )*

នៅពេលទើបបើកពិព័រណ៍ស្តង់ពិព័រណ៍របស់កញ្ញា សៅ សុភាព បានទទួលការចាប់អារម្មណ៍ពីអ្នកទស្សនាដ៏ច្រើន ។ គាត់មកពីស្រុកខ្មែរ ហើយបាននាំយកថ្នាំដុសធ្មេញម៉ាកអប្សរាមកដល់ក្រុងគុនមីង ដែលជាថ្នាំដុសធ្មេញធ្វើអំពីវត្ថុធាតុដើមធម្មជាតិសុទ្ធសាធ ។ គាត់បានបញ្ជាក់ថា យើងបានយកថ្នាំដុសធ្មេញនេះទៅលក់នៅខេត្តក្វាងស៊ី និងក្វាងតុង ហើយសង្ឃឹមថា ប្រជាជនខេត្តយូនណាននឹងអាចស្គាល់ផលិតផលពិសេសនេះ តាមរយៈការចូលរួមពិព័រណ៍ ។ ទីផ្សារខេត្តយូនណានមានសក្តានុពលដ៏ធំធេង ខ្ញុំមុខជានឹងមកម្តងទៀតនៅឆ្នាំក្រោយ ។

និស្សិតខ្មែរឈ្មោះ គឹម សុវណ្ណារិទ្ធ ធ្លាប់រៀនសូត្រនៅសាកលវិទ្យាល័យជនជាតិក្វាងស៊ី ។ គាត់និយាយភាសាចិនច្បាស់ណាស់ ហើយបានទទួលការស្វាគមន៍ និងការស្រឡាញ់ចូលចិត្តពីពាណិជ្ជករខ្មែរ ។ ជួនកាលគាត់នឹងចាកចេញពីស្តង់ពិព័រណ៍របស់ខ្លួន ដើម្បីជួយបកប្រែឱ្យពាណិជ្ជករខ្មែរផ្សេងៗទៀត ដោយមិនទារយកប្រាក់សោះ ។ ឆ្នាំនេះគាត់បានយកសម្លៀកបំពាក់ប្រពៃណីខ្មែរជាមួយមិត្តល្អរបស់គាត់ ដើម្បីដាក់តាំងពិព័រណ៍នៅក្រុងគុនមីង ។ គាត់យល់ឃើញថា ខេត្តយូនណានជាទីផ្សារដ៏ល្អប្រសើរ ដែលបង្កប់ដោយឱកាសពាណិជ្ជកម្មច្រើន ។ គាត់និយាយថា ពិតមែនតែឆ្នាំនេះយើងធ្វើជំនួញមិនបានផលល្អ តែយើងបានប្រមូលនូវបទពិសោធន៍ដ៏មានតម្លៃ ។ ទោះជាយើងមានលុយច្រើនក៏មិនអាចទិញបានបទពិសោធន៍ល្អៗបែបនេះ ដូច្នេះការទទួលបានបទពិសោធន៍ជារឿងគួរជាទីសប្បាយរីករាយជាងគេចំពោះអ្នកធ្វើជំនួញ ៕